# របាយការណ៍ស្ដីពីការតាមដានឧប្បត្តិហេតុយាយី ដល់អ្នកសារព័ត៌មាន

CCIM
cambodian center for independent media

ករណី**បៀតបៀនផ្លូវភេទ**
(១ ករណី)

ករណី**ចាប់ខ្លួន**
(២ ករណី)

**០៩**
**កត់ត្រា ឧប្បត្តិហេតុ**

ករណី**ការឃាត់ខ្លួន**
(២ ករណី)

ករណី**ការគំរាមកំហែង**
(៣ ករណី)

ករណី**ដកហូតអាជ្ញាប័ណ្ណសារព័ត៌មាន**
(១ ករណី)

# របាយការណ៍ស្ដីពីការតាមដានឧប្បត្តិហេតុយាយីដល់អ្នកសារព័ត៌មាន

មជ្ឈមណ្ឌលកម្ពុជា ដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (ស៊ីស៊ីអាយអឹម) បានបន្តតាមដាន និងកត់ត្រា នូវឧប្បត្តិហេតុនានា ដែលបានយាយីមកលើអ្នកសារព័ត៌មាននៅកម្ពុជា ចាប់ពីខែកក្កដា ដល់ខែកញ្ញា ឆ្នាំ២០២៥ ។ ចំនួនដែលបានកត់ត្រានេះ គឺជាឧបករណ៍សំខាន់សម្រាប់តាមដាន និងឆ្លើយតបទៅនឹងការបៀតបៀន មកលើអ្នកបម្រើការនៅក្នុងស្ថាប័នប្រព័ន្ធផ្សព្វផ្សាយ។

ករណីភាគច្រើនដែលត្រូវបានចងក្រងនៅក្នុងរបាយការណ៍នេះ មានផ្សារភ្ជាប់ទៅនឹងការរាយការណ៍អំពី ការប៉ះទង្គិចដោយអាវុធនៅព្រំដែនរវាងប្រទេសកម្ពុជា-ថៃ កាលពីខែកក្កដា ឆ្នាំ២០២៥កន្លងមក ព្រមទាំងការការរាយការណ៍អំពីអភិបាលកិច្ចមូលដ្ឋានដែលមានសម្ពាធពីអាជ្ញាធរ និងបញ្ហាសង្គមដែលជាកង្វល់របស់សាធារណជន។




## ស៊ីស៊ីអាយអឹមបានកត់ត្រាឧប្បត្តិហេតុចំនួន០៩ ករណី

រយៈពេលបីខែនៃត្រីមាសទីបីឆ្នាំ២០២៥នេះ ស៊ីស៊ីអាយអឹម បានកត់ត្រាឧប្បត្តិហេតុចំនួន **០៩ ករណី** ដែលប៉ះពាល់ដល់អ្នកសារព័ត៌មានអាជីព និងអ្នកសារព័ត៌មានពលរដ្ឋចំនួន ១០ នាក់ (១នាក់ស្ត្រី) និងអាជ្ញាប័ណ្ណសារព័ត៌មានចំនួន ១ ផងដែរ ។

ឧប្បត្តិហេតុទាំងនេះ ពាក់ព័ន្ធ**ករណីបៀតបៀនផ្លូវភេទ**លើស្ត្រីជាអ្នកសារព័ត៌មានពលរដ្ឋ ១ករណី **ការឃាត់ខ្លួន** ២ករណី **ការគំរាមកំហែង** ៣ករណី **ការដកហូតអាជ្ញាប័ណ្ណសារព័ត៌មាន** ១ករណី និង**ករណីចាប់ខ្លួន** ២ករណី ក្រោយការចុះផ្សាយអំពីជម្លោះព្រំដែន ត្រូវបានចោទប្រកាន់ពីបទក្បត់ជាតិ ។

ករណីបែបនេះឆ្លុះបញ្ចាំងពីការគម្រាមកំហែងជាបន្តបន្ទាប់ចំពោះ**សេរីភាពសារព័ត៌មាន** និង**គាបសង្កត់ធ្ងន់**លើតម្រូវការបន្ទាន់សម្រាប់ការការពារកាន់តែរឹងមាំ និងបរិយាកាសដែលអ្នកសារព័ត៌មាន ទូទាំងប្រទេស អាចធ្វើការដោយសេរី និងសុវត្ថិភាពសម្រាប់អ្នកសារព័ត៌មានទូទាំងប្រទេស។

## ឧប្បត្តិហេតុសំខាន់ៗដែលកើតឡើងរួមមាន៖

***ករណីទី១៖*** ស្ត្រីជាអ្នកសារព័ត៌មានពលរដ្ឋ ត្រូវបានបុរសស្រវឹងស្រាម្នាក់ធ្វើសកម្មភាពមិនសមរម្យមកលើ រូបគាត់ ខណៈកំពុងចុះយកព័ត៌មាននៅក្នុងសហគមន៍នៅខេត្តស្ទឹងត្រែង។

ដើម្បីសម្ភាសន៍ប្រភពក្នុងអត្ថបទព័ត៌មានរបស់គាត់ គាត់ត្រូវធ្វើដំណើរចម្ងាយប្រហែល ៣០ គីឡូម៉ែត្រពីកន្លែងរស់នៅ ដើម្បីជួបប្រភព នៅទីតាំងដែលនៅភូមិក្បែរនោះ។

បន្ទាប់ពីចតម៉ូតូរួចគាត់ក៏ដើរទៅផ្ទះរបស់អ្នកដែលត្រូវផ្តល់បទសម្ភាសន៍។ ពេលនោះ មានបុរសស្រវឹងស្រាម្នាក់បានធ្វើសកម្មភាពមិនសមរម្យមកលើរូបគាត់។ ក្រោយពេលកើតហេតុភ្លាមគាត់បានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរឃុំ ប៉ុន្តែគាត់មិនអាចកំណត់ អត្តសញ្ញាណជនបង្កហេតុបាន។

នេះគឺជាទម្រង់មួយនៃការបៀតបៀនផ្លូវភេទ ដែលនៅតែបន្តកើតមាន លើស្ត្រី និងធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពរបស់អ្នកសារព័ត៌មាន ស្ត្រីក្នុងវិស័យសារព័ត៌មាន។

CCIM
cambodian center for independent media

# របាយការណ៍ស្ដីពីការតាមដានឧប្បត្តិហេតុយាយីដល់អ្នកសារព័ត៌មាន

***ករណីទី២៖*** អ្នកសារព័ត៌មានពលរដ្ឋ បានទទួល ការទូរសព្ទចូលជាច្រើនលើកពីអាជ្ញាធរឃុំនិងស្រុក បន្ទាប់ពីរាយការណ៍អំពីការខូចខាតផ្លូវក្នុង សហគមន៍ របស់ពួកគេ ។ អ្នកសារព័ត៌មានពលរដ្ឋ បានចុះផ្សាយវីដេអូព័ត៌មាន រំលេចអំពីការត្អូញត្អែររបស់ប្រជាពលរដ្ឋនៅស្រុករវៀង ដែលរៀបរាប់ពីផ្លូវខូច ធ្វើឱ្យការធ្វើដំណើរពិបាក និងស្នើសុំអោយអាជ្ញាធរ ជួយជួសជុល។ វីដេអូនេះមានការទាក់ទាញនិងចូលទស្សនាជាច្រើនពីសាធារណៈជននៅលើ ទំព័រ ហ្វេសប៊ុកព័ត៌មានពលរដ្ឋ។

ទោះជាយ៉ាងណា មេឃុំ បានហៅទូរសព្ទទៅកាន់អ្នកសារព័ត៌មានពលរដ្ឋ និងបាននិយាយគំរាមដល់សុវត្ថិភាព និងសួរនាំអំពីអាជ្ញាប័ណ្ណសារព័ត៌មានរបស់គាត់។ លោកទាមទារឲ្យ លុបវីដេអូនោះចេញដោយមិនបានបង្ហាញពីមូលហេតុ ច្បាស់លាស់ឬមានការពន្យល់អំពីផ្នែកណាដែល បំពាន ក្រមសីលធម៌វិជ្ជាជីវៈអ្នកសារព័ត៌មាន ឬ គោលការណ៍អ្នកសារព័ត៌មាននោះទេ។

បន្ទាប់ពីអាជ្ញាធរ មូលដ្ឋានកំណត់អត្តសញ្ញាណនៃប្រភពនៃរបាយការណ៍នេះគ្រូបណ្តុះបណ្តាល ស៊ីស៊ីអាយអឹម បាទាក់ទង ទៅមន្ត្រីពាក់ព័ន្ធ ដើម្បីសុំបំភ្លឺអំពីបញ្ហានេះ និងពិភាក្សាអំពីវីដេអូដែលបានចុះផ្សាយ។ បន្ទាប់ពីការ ពិភាក្សា ស៊ីស៊ីអាយអឹមបានរកឃើញព័ត៌មានដែលផលិតដោយពលរដ្ឋសារព័ត៌មានមិនមានកំហុសនោះទេ។

លោកមេឃុំ បានបំភ្លឺថា លោកគ្រាន់តែចង់ឱ្យពលរដ្ឋសារព័ត៌មានសុំការឆ្លើយតបពី ពីក្រុមហ៊ុនឈ្មោះ **“ធី ង៉ា”** ដែលជាអ្នកទទួលខុសត្រូវលើការជួសជុលផ្លូវ ដែលរងការខូចខាតក្រោមកិច្ចព្រមព្រៀង ប្រតិបត្តិការ របស់ខ្លួន។

បញ្ហានេះត្រូវបានដោះស្រាយតាមរយៈការសន្ទនាតាមទូរស័ព្ទ ហើយអាជ្ញាធរបាន បញ្ជាក់ថាពួកគេនឹងស្វាគមន៍ការរាយការណ៍នាពេលខាងមុខ ប៉ុន្តែបានស្នើឱ្យអ្នកសារព័ត៌មានពលរដ្ឋពិគ្រោះយោបល់ជាមួយមន្ត្រីមូលដ្ឋានមុននឹងផ្សព្វផ្សាយ។

***ករណីទី៣៖*** អ្នកសារព័ត៌មានអនទ្បាញពីររូប មកពីសារព័ត៌មាន TSP 68 TV Online គឺ ផុន សុភាព និង លោក ភាព ភារ៉ា មកពីសារព័ត៌មាន Battambang Post TV Online ត្រូវបានចាប់ខ្លួនកាលពីខែ កក្កដា ឆ្នាំ២០២៥ បន្ទាប់ពីរាយការណ៍នៅជិតតំបន់ជម្លោះព្រំដែនកម្ពុជា-ថៃ ។

អ្នកសារព័ត៌មានទាំងពីរនាក់ត្រូវ បានចោទប្រកាន់ពីបទក្បត់ជាតិតាមមាត្រា ៤៤៥ នៃ ក្រម ព្រហ្មទណ្ឌ ដោយសារការបង្ហោះព័ត៌មានៅលើបណ្តាញសង្គម។ ប្រសិនបើតុលាការរកឃើញថាមានបទល្មើស ពួកគាត់អាចនឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី០៧ទៅ១៥ឆ្នាំ។

បច្ចុប្បន្នអ្នក សារព័ត៌មានទាំង ពីរ កំពុង ឃុំ ខ្លួនជាបណ្តោះអាសន្ន នៅ ពន្ធនាគារខេត្តសៀមរាប ។ ការបង្ហោះរូបភាពនៅលើបណ្តាញសង្គមដែលនាំទៅដល់ការចាប់ខ្លួនពួកគេនៅតែមានភាពមិនច្បាស់លាស់ទោះបីជាមានរូបថតមួយសន្លឹករបស់ពួកគេជាមួយទាហានខ្មែរនៅជិត*ប្រាសាទតាក្របី ដែលត្រូវបានគេជឿថាមានការផ្សារភ្ជាប់នឹងករណីនេះក៏ដោយ។*

ដើម្បីពង្រឹងសុវត្ថិភាពអ្នកសារព័ត៌មាន ស៊ីស៊ីអាយអឹម នឹងបន្តតាមឧប្បត្តិហេតុដែល កើតឡើងលើ អ្នកធ្វើការក្នុងប្រព័ន្ធផ្សព្វផ្សាយ និងផ្តល់ជំនួយផ្នែកច្បាប់ដល់ អ្នកដែលប្រឈមនឹងហានិភ័យ។ អ្នកអាចរាយការណ៍ពីឧប្បត្តិហេតុនានា ឬស្នើសុំជំនួយផ្នែកច្បាប់តាមរយៈលេខទូរសព្ទ៖ **០៦០ ៥០ ៥០ ៥០។**